SSLS

# របាយការណ៍ប្រចាំឆ្នាំ

ឈ្មោះគ្រោងការ : សេវាជួយជនរងគ្រោះដោយសារមីន

របាយកាណ៏ជូន : ឯកឧត្តម យី វាសនា នាយកប្រតិបត្តិមជ្ឈមណ្ឌលជាតិជនពិការ

របាយកាណ៏ដោយ : លោក គាន អូរ៉ អ្នកសំរបសំរួលសហគមន៏ខេត្តបាត់ដំបង

រយៈពេល : ខែ មករា-ធ្នូ ២០០០៩

គ្រោងការណ៏ជួយជនរងគ្រោះដោយសារមីនគឺជួយជនពិការដោយសារមីន ដូចជាបង្កើតមុខរបរ សាងសង់ផ្ទះ និងជួសជុលផ្ទះជូនជនពិការ តាមទិដ្ឋភាពជាក់ស្តែងធ្វើយ៉ាងណាអោយគាត់មានជីវភាពសមរម្យ ដើម្បីនិរន្តន៍ភាពនៃមុខរបររបស់គាត់ ។

## ១.សកម្មភាពសង្ខេប

-ចូលរួមប្រជុំជាមួយលោកអនុប្រធានមន្ទីរសង្គមកិច្ច

-ចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំនិងមេភូមិក្នុងឃុំជ្រៃ

-ចូលរួមប្រជុំជាមួយអង្គការដែលពាក់ព័ន្ធនិងវិស័យពិការភាព

-សកម្មភាពចុះជួយជនពិការ

-សកម្មភាពចុះជួបជនពិការរបស់ឯកឧត្តមនាយក

-ការបង្កើតគណៈកម្មកាណ៏អភិវឌ្ឍន៏ជនពិការឃុំ

-សកម្មភាពចុះតាមដានជនពិការដល់លំនៅដ្ឋាន

## ២. សមិទ្ធិផលនិងជោគជ័យ

-ខ្ញុំបានចូលរួមប្រជុំជាមួយលោកអនុប្រធានមន្ទីរសង្គមកិច្ចដើម្បីបង្ហាញលំអិតពីគំរោងSSLSដែលជាគំរោងថ្មីរបស់ NCDP ដែលមានសកម្មភាពចុះជួយបង្កើតមុខរបរ ផ្តល់សំភារៈនិងជួយសាងសង់ផ្ទះដល់គាត់ជាប្រយោជន៍ដើម្បីអោយគាត់មានជីវភាពសមរម្យនិងកាត់បន្ថយភាពរើងអើងក្នុងសហគមន៏របស់គាត់ ។ ដោយឡែកក្នុងកិច្ចប្រជុំនោះលោកអនុប្រធានមានការចាប់អារម្មណ៏យ៉ាងខ្លាំងក្នុងការធ្វើការសហការជាមួយNCDP ក្នុងនោះដែលលោកបានស្នើរសុំអោយរូបខ្ញុំចូលរួមកិច្ចប្រជុំមួយខែម្តងជាមួយនិងអង្គការដែលពាក់ព័ន្ធនិងវិស័យពិការភាពក្នុងខេត្តបាត់ដំបងនិងបានផ្តល់ឈ្មោះមន្ត្រីសង្គមកិច្ចស្រុកដើម្បីសហការជាមួយរូបខ្ញុំ ។

-ខ្ញុំបានចូលរួមកិច្ចប្រជុំជាមួយក្រុមប្រឹក្សាឃុំនិងលោកមេភូមិទាំងអស់ក្នុងឃុំជ្រៃក្នុងកិច្ចប្រជុំនោះលោកមេឃុំបានលើកឡើងពីផែនការណ៏អភិវឌ្ឍន៏ឃុំនិងកញ្ចប់ថវិការសំរាប់អភិវឌ្ឍន៏សហគមន៏និងជនពិការ ។ ក្នុងកិច្ចប្រជុំរូបខ្ញុំបានបង្ហាញពីគំរោងSSLS ជូនដល់អង្គប្រជុំទាំងមូលមានលោកមេឃុំនិងមេភូមិ ។

-ខ្ញុំបានចូលរួមជាមួយអង្គការដែលពាក់ព័ន្ធនិងវិស័យពិការភាពដែលរៀបចំឡើងដោយអង្គការ HIF នៅមន្ទីរសុខាភិបាលខេត្តក្រោមប្រធានបទការរំលោភផ្លូវភេទលើស្ត្រីពិការ ។ នៅក្នុងកិច្ចប្រជុំអង្គការ HIF បានបង្ហាញអំពីសកម្មភាពរបស់គំរោងទៅកាន់អ្នកចូលរួម ។

## ៣. សកម្មភាពចុះជួយជនពិការ

ពីខែ មករា ដល់ ធ្នូ ២០០៩ SSLS បានជួយជនពិការក្នុងខេត្តបន្ទាយមានជ័យ ប៉ៃលិន និង បាត់ដំបង បានចំនួន **៧៦នាក់ ស្រី ៦ នាក់**

**-បាត់ដំបងជួយជនពិការដោយសារមីនចំនួន ៣៥ នាក់**

**-ប៉ៃលិនជួយជនពិការដោយសារមីនចំនួន ២៦ នាក់**

**-បន្ទាយមានជ័យជួយជនពិការដោយសារមីនចំនួន ១៥នាក់**

## ៤. សកម្មភាពចុះជួបជនពិការរបស់ឯកឧត្តមនាយក

-នៅថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០០៩ ឯកឧត្តម យី វាសនាបានចុះមកខេត្តបាត់ដំបងដើម្បីជួយជុំសំណេះសំណាលជាមួយបងប្អូនជនពិការចំនួន ២២០នាក់ ។ ក្នុងពិធីនោះ ឯកឧត្តមបាននាំយកមកជាមួយ ម៉ាស៊ីនស្ទប់ ១ កង់ចំនួន ៥ គ្រឿង សៀវភៅសំរាប់កុមារពិការនិងងាយរងគ្រោះចំនួន ២០០ក្បាល ព្រមទាំងម្នាក់ៗទទួលបានថវិការចំនួន ៨០០០រៀល ។

## ៥. ការបង្កើតគណៈកម្មកាណ៍អភិវឌ្ឍន៍ជនពិការឃុំ

-គំរោងជួយជនរងគ្រោះដោយសារមីនខេត្តបាត់ដំបងបានបង្កើតគណៈកម្មការណ៍អភិវឌ្ឍន៍ជនពិការឃុំ ជ្រៃ និង ឃុំ អូម៉ាល់ ដែលមួយឃុំ មាន ប្រធាន ម្នាក់ និងអនុប្រធាន២នាក់ដែល ជាតំណាងអោយជនពិការ ។

## ៦. សកម្មភាពចុះតាមដានជនពិការដល់លំនៅដ្ឋាន

- ជនពិការដែលបានទទួលសេវាកម្មពីគ្រោងការ សេវាសង្គមជួយជនរងគ្រោះដោយសារគ្រាប់មីន ( SSLS ) ពួកគាត់ ខំប្រឹងប្រែងព្យាយាមយកចិត្តទុកដាក់ប្រកប់មុខរបរដែលបានផ្តល់ជូនដើម្បីអោយជីវភាពមានការរីកចំរើន និងចូរចារួចមកពួកគាត់ក៏មានទឹកចិត្តសប្បាយរីករាយប្រកបដោយសេចក្តីសុខក្នុងគ្រួសាររបស់គាត់ ។ ហើយពួកគាត់អាយមានលទ្ធភាពជូនកូនរបស់ពួកគាត់ទៅសាលារៀនផងដែរ ។

## ៧. សកម្មភាពឆ្នាំ ២០១០

-បន្តចុះសំភាសន៍ជនពិការថ្មីទៀត

-បង្កើតគណៈកម្មការអភិវឌ្ឍន៍ជនពិការនៅឃុំដ៏ទៃទៀត